លេខ៖០០៧៣/១៥ ស.អ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការទទួលបន្ទុកការងារវិន័យនិងក្រមសីលធម៌
## (Code of Conduct and Ethics Executive Committee)

## ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

- បានឃើញនៅអនុក្រឹត្យ ស្តីពី "**ការទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជា**" លេខ **២២៨** អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ ដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាត កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់ របស់សហព័ន្ធស្រូវអង្ករកម្ពុជា

## សម្រេច

**ប្រការ១.**

បង្កើតគណៈកម្មាធិការ ទទួលបន្ទុកការងារវិន័យនិងក្រមសីលធម៌ (Code of Conduct and Ethics Executive Committee) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក នង វិសនា | នាយកក្រុមហ៊ុន NKL | ប្រធាន |
| ២. លោក កាន់ គន្ធី | នាយកប្រតិបត្តិ BRICO | អនុប្រធាន |
| ៣. លោក ចាន់ សុឃាំង | នាយកក្រុមហ៊ុន SOA | សមាជិក |
| ៤. លោក ហេង ផេង | រោងម៉ាស៊ីន សៀ ហេង | សមាជិក |
| ៥. លោក ហ៊ាង គីមសួរ | រោងម៉ាស៊ីនកិនស្រូវអៀងហ៊ាង | សមាជិក |
| ៦. លោក រិន សីហា | រោងម៉ាស៊ីនកិនស្រូវ Carma rice Limited | សមាជិក |
| ៧. លោក ឡាយ ឈុនហួ | នាយកក្រុមហ៊ុន CITY RICE | សមាជិក |
| ៨. លោក ចាន់ វុទ្ធី | នាយកក្រុមហ៊ុន T.O.T | សមាជិក |
| ៩. លោក សែ ឡាឡែន | រោងម៉ាស៊ីន ហាក់សែ | សមាជិក |
| ១០. លោក រស់ សុផារទ្ធិ | រោងម៉ាស៊ីនកិនស្រូវ កំពង់ធំ | សមាជិក |
| ១១. លោក វង្ស ឈិវ | ប្រធានក្រុមហ៊ុន Hung Hiep (Cambodia) | សមាជិក |
| ១២. លោក ឈុន ធំ | រោងម៉ាស៊ីនកិនស្រូវឈុន ធំ | សមាជិក |
| ១៣. លោក អេល សោត | តំណាងក្រុមហ៊ុនសុខកែវ | សមាជិក |
| ១៤. លោក យ៉ាន ពេជ្រ | មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្ត លើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ តាមការងារដូចខាងក្រោម៖

- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការរៀបចំផែនការយុទ្ធសាស្រ្ត និងអនុវត្តវិធានការជម្រុញការទប់ស្កាត់ការនាំអង្ករពីប្រទេសជិតខាងដែលមិនត្រឹមត្រូវតាមច្បាប់ ក្នុងការផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុកនិងកែច្នៃ ដើម្បីនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។
- ទទួលបន្ទុកការងារវិន័យ និងអធិការកិច្ចនៃក្រមសីលធម៌ដោយជំរុញអោយគ្រប់សមាជិកទាំងអស់អនុវត្ត និងគោរពតាមក្របខណ្ឌក្រមសីលធម៌និងគោលការណ៍នៃការងាររួមមាន សុចរិតភាព តម្លាភាព ការអនុវត្តជាក់ស្តែង ភាពលឿន សាមគ្គីភាព និងរក្សាអោយបាននូវស្តង់ដារសីលធម៌ខ្ពស់បំផុតក្នុងសកម្មភាពជំនួញជាមួយភាគីពាក់ព័ន្ធទាំងអស់។
- កំណត់ពីផែនការ និងនីតិវិធីក្នុងការដាក់ពិន័យចំពោះសមាជិកណាដែលមិនបានអនុវត្តតាមក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់សហព័ន្ធស្រូវអង្ករកម្ពុជា
- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចរចារជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័នជាតិ ភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការស្វែងរកនូវវិធានការទប់ស្កាត់និងការដាក់ពិន័យដល់អ្នកដែលនាំអង្ករពីប្រទេសជិតខាងមិនត្រឹមត្រូវតាមច្បាប់ និងការធ្វើសកម្មភាពជំរុញការផ្សព្វផ្សាយ ការងារអប់រំពន្យល់ដល់អ្នកពាក់ព័ន្ធអំពីផលប៉ះពាល់ក្នុងការនាំអង្ករពីប្រទេសជិតខាង ទាំងការប្រើប្រាស់ក្នុងស្រុក និងកែច្នៃដើម្បីនាំចេញបន្តទៅកាន់ទីផ្សារអន្តរជាតិ ក្រោមរូបភាពម៉ាកអង្ករកម្ពុជា។
- គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណីការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលឲ្យអនុញ្ញាតសម្រេចជាមុនសិន។
- ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសំរាប់គណៈកម្មាធិការទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។

**ប្រការ៣.**

ក្រុមប្រឹក្សាភិបាល សមាជិក សមាជិកា លេខាធិការដ្ឋាន ស.អ.ក និងការិយាល័យសាខាតាមខេត្ត និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៥

**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

<u>ចម្លងជូន៖</u>

- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា( ការិយាល័យតាមច្រកព្រំដែននានា )
- គម្រោងពាណិជ្ជកម្មស្រូវនៅកម្ពុជា របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ